រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## "ប្រព័ន្ធពន្ធដារកម្ពុជានិងបរិយាកាសវិនិយោគនៅកម្ពុជា" ជូនដល់តំណាងសហគ្រិនធុនតូចនិងមធ្យមនៃព្រះរាជាណាចក្រថៃឡង់ដ៍




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

តបតាមការអញ្ជើញរបស់លោក Prasong Poontaneat អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រថៃឡង់ដ៍ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារដឹកនាំដោយ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដំណើរដោយលោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមន្ត្រីពាក់ព័ន្ធមួយចំនួនត្រូវបានអញ្ជើញធ្វើជាវាគ្មិនកិត្តិយស ដើម្បីចូលរួមសិក្ខាសាលាស្តីពី "ប្រព័ន្ធពន្ធដារកម្ពុជា និងបរិយាកាសវិនិយោគនៅកម្ពុជា" ដែលរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារនៃព្រះរាជាណាចក្រថៃឡង់ដ៍ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៦ នៅព្រះរាជាណាចក្រថៃឡង់ដ៍។

សិក្ខាសាលានេះមានគោលដៅណែនាំ និងជម្រុញវិនិយោគិនព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងការពង្រីកការវិនិយោគនៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម (CLMV)។ ជាពិសេស សិក្ខាសាលានេះមានការចូលរួមស្តាប់និងពិភាក្សាយ៉ាងផុសផុលពីតំណាងថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រថៃឡង់ដ៍ តំណាងមកពីក្រុមហ៊ុនស្នងការគណនេយ្យនានា ព្រមទាំងសហគ្រាសធុនតូច និងមធ្យមជាច្រើនដែលសហគ្រាសទាំងនេះភាគច្រើនកំពុងធ្វើធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមួយចំនួនទៀតកំពុងសិក្សាគម្រោង ធ្វើការបណ្តាក់ទុនវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈវេទិការ SMEs នេះ វាជាការ ពង្

រឹងសមត្ថភាពក្នុងការប្រកួតប្រជែងការវិនិយោគ នៅក្នុងចំណោមបណ្តាប្រទេស CLMV កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។

ក្នុងកិច្ចដំណើរការសិក្ខាសាលានេះ ក៏មានការធ្វើបទបង្ហាញដោយផ្ទាល់ពីសំណាក់ ឯកឧត្តម **គង់ វិបុល** ដោយផ្តោតសំខាន់លើប្រព័ន្ធពន្ធដារកម្ពុជា ជាពិសេសការធ្វើកំណែទម្រង់ពន្ធដារទាំងផ្នែកគោលនយោបាយ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលសម្រេចបាននូវការកែលម្អនូវអភិបាលកិច្ចសំរាប់ការប្រមូលពន្ធ កែលម្អការផ្តល់សេវាជូនអ្នកជាប់ពន្ធ កែលម្អរដ្ឋបាលសារពើពន្ធ ការលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ ព្រមទាំងអនុវត្តតាមគោលនយោបាយរដ្ឋាភិបាល ក្នុងការមិនបង្កើតប្រភេទពន្ធថ្មីឬតំឡើងអត្រាពន្ធអាករនោះទេ។ ជាមួយគ្នានេះដែរឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានធ្វើការពន្យល់បកស្រាយពន្យល់អំពីច្បាប់ និងបទប្បញ្ញត្តិនានា ពាក់ព័ន្ធនឹងពន្ធដារកម្ពុជាអំពីវឌ្ឍនភាពថ្មីៗទាក់ទិននឹងការរៀបចំធ្វើវិសោធនកម្មច្បាប់សារពើពន្ធ ក៏ដូចជាច្បាប់វិនិយោគ និងច្បាប់នានាផ្សេងទៀត ដែលពាក់ព័ន្ធ ក្នុងគោលដៅឱ្យច្បាប់ទាំងនោះមានសង្គតិភាព និងផ្តល់នូវការលើកទឹកចិត្តស្របទៅនឹងបរិយាកាសធុរកិច្ចជាក់ស្តែងនៅកម្ពុជា។

ជាមួយគ្នានោះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត បញ្ញាញាណដ៏ឈ្លាសវៃរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបាននឹងកំពុងកសាងមូលដ្ឋានគ្រឹះ សម្រាប់កំណើនសេដ្ឋកិច្ចការលើកកម្ពស់ការអភិវឌ្ឍសង្គមអភិបាលកិច្ចល្អ ការអភិវឌ្ឍធនធានមនុស្ស កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលទាំងអស់នេះ គឺត្រូវបានអនុវត្តឡើងព្រមៗគ្នា ដើម្បីជម្រុញដល់ការភ្ជាប់ទំនាក់ទំនងរវាងកម្ពុជាជាមួយនឹងបណ្តាប្រទេសផ្សេងទៀត នៅក្នុងតំបន់លើក្របខណ្ឌ នៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ដើម្បីឱ្យមានភាពជិតស្និទ្ធ និងស្វែងយល់ពីគ្នាទៅវិញទៅមក ក្នុងអង្គសិក្ខាសាលានេះ ក៏បានអនុញ្ញាតឱ្យវិនិយោគិននៃប្រទេសថៃឡង់ដ៏ ធ្វើការចែករំលែកបទពិសោធន៍និងលើកឡើង នូវសំណូមពរ ព្រមទាំងបើកទូលាយ ចំពោះសំណួរផ្សេងៗពាក់ព័ន្ធទៅនឹងពន្ធដារ ក្នុងន័យជួយសម្រួលដល់ការវិនិយោគនៅកម្ពុជាផងដែរ។

អគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រថៃឡង់ដ៏ បានចាត់ទុកអង្គសិក្ខាសាលាមួយនេះថា ពិតជាមានសារៈសំខាន់ជាខ្លាំង ចំពោះសហគ្រាសនានា ដែលមានបំណងមកធ្វើការវិនិយោគនៅកម្ពុជា៕




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ